## ជំហានទី 4 – ផ្ញើ

1. បំពេញឱ្យចប់សព្វគ្រប់លើទម្រង់បែបបទព័ត៌មានពិស្តាររបស់អ្នកចូលរួម។




2. សរសេរឈ្មោះ និងអាសយដ្ឋាននៅខាងក្រោយស្រោមសំបុត្រឆ្លើយតបដែលគេបានបង់ប្រាក់ហើយ និងចុះហត្ថលេខានៅផ្នែកខាងមុខ។



3. ដាក់ទម្រង់បែបបទព័ត៌មានពិស្តារ និងបំពង់ប្រមូលសំណាកគំរូទាំងពីរ (នៅក្នុងថង់ដែលមានខ្សែចងរូត ដែលបានបិទជិត) ចូលទៅក្នុងស្រោមសំបុត្រឆ្លើយតបដែលគេបានបង់ប្រាក់ហើយ និងបិទវា ជិត។




4. យកស្រោមសំបុត្រនោះទៅកាន់ការិយាល័យប្រៃសណីយ **នៅក្នុងរយៈពេល 24** ម៉ោង ឬផ្ញើ **ពេលល្ងាច (នៅមុនម៉ោង 6)** ដោយប្រើប្រាស់ប្រអប់សំបុត្រផ្ញើរបស់ប្រៃសណីយអូស្ត្រាលី។



សំណាកគំរូត្រូវតែនៅត្រជាក់ជានិច្ច ដូច្នេះមិនត្រូវទុកវាចោលនៅក្នុងកន្លែងក្តៅទេ ដូចជានៅក្នុងឡានជាដើម។

### សំណួរ

ប្រសិនបើលោកអ្នកមានសំណួរនានាស្តីពីរបៀបដើម្បីធ្វើតេស្ត សូមហៅ ខ្សែទូរសព្ទជំនួយសម្រាប់កញ្ចប់ សម្ភារៈធ្វើតេស្តតាមលេខ **1800 930 998** (ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង7.30 ព្រឹក - 10 ល្ងាច ម៉ោង AEST/AEDT និងថ្ងៃសៅរ៍ ដល់ថ្ងៃអាទិត្យ ម៉ោង 9 ព្រឹក - 7 ល្ងាច ម៉ោង AEST/AEDT) ឬមើលវីដេអូខ្លីនៅឯ **www.cancerscreening.gov.au/bowel**

### ការបកប្រែសរសេរ

សម្រាប់ព័ត៌មានជាភាសារបស់លោកអ្នក សូមចូលមើល www.cancerscreening.gov.au/translations ឬហៅទូរសព្ទទៅ សេវាបកប្រែសរសេរ និងបកប្រែផ្ទាល់មាត់ តាមលេខ **13 14 50**។

### លទ្ធផលរបស់លោកអ្នក

លទ្ធផលរបស់លោកអ្នកនឹងត្រូវបានផ្ញើទៅលោកអ្នក និងវេជ្ជបណ្ឌិតរបស់លោកអ្នក (បើបានតែងតាំង) នៅក្នុងរយៈពេលពីរបីសប្តាហ៍ ក្រោយពីលោកអ្នកបានផ្ញើសំណាកគំរូរបស់លោកអ្នក តាមប្រៃសណីយហើយ។


សេវារោគសាស្ត្រ

SONIC HEALTHCARE
Quality is in our DNA

អ្នកជានាផ្តល់ប្រាក់

r-biopharm

34 WOODFIELD BOULEVARD CARINGBAH NSW 2229

អ្នកផលិត

EIKEN CHEMICAL CO., LTD.


www.cancerscreening.gov.au

Australian Government

NATIONAL BOWEL CANCER SCREENING PROGRAM

# កញ្ចប់សម្ភារៈសម្រាប់ធ្វើតេស្តនៅផ្ទះ

## សេចក្តីណែនាំ

ជំហាន 4 យ៉ាងដែលអាចជួយសង្គ្រោះជីវិតរបស់លោកអ្នក។

**ទូរសព្ទជំនួយសម្រាប់កញ្ចប់សម្ភារៈធ្វើតេស្តលេខ1800 930 998**

**www.cancerscreening.gov.au**

# សេចក្ដីណែនាំ

## កញ្ចប់សម្ភារៈរបស់លោកអ្នក មាន




2 x ទ្រនាប់បង្គន់



2 x បំពង់ផ្ទុកសំណាកគំរូ



1 x ថង់ដែលមានខ្សែរូតបិទ




1 x ស្រោមសំបុត្រឆ្លើយតបបង់ប្រាក់ហើយ

## មុនពេលលោកអ្នកចាប់ផ្ដើម

### កិច្ចការសំខាន់ៗដែលលោកអ្នកត្រូវដឹង

✓ លោកអ្នកមិន បាច់ធ្វើការផ្លាស់ប្ដូរ របបអាហារ ឬថ្នាំរបស់លោកអ្នកទេ។

✓ លោកអ្នកត្រូវ ប្រមូលយកសំណាកគំរូតិចៗពីលាមក ២ដងពីការបត់ជើង២ដងខុសគ្នា។ ការបត់ជើងទាំង២ដងនោះ សុំយកការបត់ជើងដែលនៅជិតគ្នាបំផុតដែលអាចធ្វើបាន។

✓ ស្តុកទុកសំណាកគំរូដែលបានយករៀបរយហើយក្នុងសីតុណ្ហភាពរវាង 2°C និង 8°C (ដែលល្អបំផុតគឺដាក់ក្នុងទូទឹកកកក៏ប៉ុន្តែកុំដាក់ឱ្យវាកក) រហូតដល់ពេលលោកអ្នកផ្ញើសំណាកគំរូទាំងនោះតាមប្រៃសណីយ៍។

## សូមកុំ ធ្វើតេស្ត ប្រសិនបើលោកអ្នកមាន៖

✘ ឫសដូងបាត (ជំងឺឫសដូងបាត) ដែលកំពុងចេញឈាម។ ប្រសិនបើ ការនេះកើតមានឡើង សូមទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក។

✘ មានឈាមនៅក្នុងទឹកនោម នៅក្នុងលាមក ឬនៅក្នុងចានបង្គន់របស់លោកអ្នក។ ប្រសិនបើ ការនេះកើតមានឡើង សូមទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក។

✘ អំឡុងពេលមករដូវរបស់អ្នក។ សូមរង់ចាំយ៉ាងហោចណាស់បីថ្ងៃ បន្ទាប់ពីផុតរដូវរបស់អ្នក មុននឹង ធ្វើតេស្ត។

## ជំហានទី 1 – រៀបចំត្រៀម

1. នៅលើស្លាកសម្គាល់បំពង់មួយនៃបណ្ដាស្លាកសម្គាល់បំពង់នានា ត្រូវសរសេរ
   - ឈ្មោះពេញរបស់លោកអ្នកនៅចំណុច [N]
   - ថ្ងៃ ខែ កំណើតនៅចំណុច [A]
   - កាលបរិច្ឆេទដែលលោកអ្នកយកសំណាកគំរូនៅចំណុច [D]




2. នៅមុនពេលនឹងប្រមូលយកសំណាកគំរូរបស់លោកអ្នក បង្ហូរចេញឱ្យអស់ផ្លោកនោមរបស់អ្នក (ត្រូវនោម) រួចហើយចុចទឹកលាងបង្គន់។



3. ដាក់ទ្រនាប់បង្គន់នៅលើទឹកនៅក្នុងចាន បង្គន់។ សរសេរអក្សរត្រូវឲ្យបែរឡើងលើ។



4. ប្រសិនបើ ទ្រនាប់បង្គន់នោះលិចទឹក ក៏វានៅតែមិនអីទេក្នុងការយកសំណាកគំរូ ឬមួយក៏លោកអ្នកអាចស្នើសុំកញ្ចប់សម្ភារៈថ្មីក៏បាន។

## ជំហានទី 2 – ប្រមូលសំណាកគំរូ

1. ជុះដាក់ លើទ្រនាប់បង្គន់។



2. បើកបំពង់ប្រមូលសំណាកគំរូ ដោយ **មួល** គម្របពណ៌បៃតង។



3. យកចុងបន្ទះឈើទៅកោសលើផ្នែកផ្សេងៗគ្នានៃផ្ទៃលាមក។

   ត្រូវការតែសំណាកគំរូដែលមានទំហំតូចៗប៉ុណ្ណោះ – គឺតូចជាងគ្រាប់អង្ករមួយគ្រាប់។



4. ដាក់បន្ទះឈើត្រឡប់ចូលទៅក្នុងបំពង់ប្រមូលសំណាកគំរូវិញ ហើយ **សង្កត់គម្របបិទវា។**

   **ក្រឡុក**បំពង់ទៅលើ និងចុះទៅក្រោមជាច្រើនដង។ សូមកុំយកចេញបន្ទះឈើនោះម្ដងទៀត។



5. ចុចទឹកលាង បង្គន់ឲ្យទ្រនាប់បង្គន់និងលាមកហូរចេញទៅ។

   លាងដៃរបស់លោកអ្នក។



## ជំហានទី 3 – ស្តុកទុក និងធ្វើម្ដងទៀត



1. ដាក់បំពង់ចូលទៅក្នុងថង់ដែលមានខ្សែរូតបិទ។

2. ដាក់សំណាកគំរូក្នុងទូទឹកកក។ **(កុំដាក់ឱ្យកក)**។

3. **ធ្វើ ជំហានទី 1 – 3 ម្ដងទៀត** ដោយប្រើបំពង់ប្រមូលសំណាកទីពីរនៅពេលដែលលោកអ្នកត្រូវបត់ជើងធំម្ដងទៀត (ក្នុងថ្ងៃដដែល ថ្ងៃបន្ទាប់ ឬធ្វើឱ្យបានលឿនដូចដែលលោកអ្នកអាចធ្វើទៅបាន)។



*សូមត្រឡប់ទៅជំហានទី4។*

*“ការធ្វើតេស្តនេះអាចស្ដាប់ទៅដូចជាមិនគួរឱ្យទាក់ទាញចិត្តទេ ក៏ប៉ុន្តែវាស្អាត និងងាយស្រួល ហើយអាចជួយសង្គ្រោះជីវិតរបស់លោកអ្នកបាន។ វាគ្រាន់តែត្រូវការការទៅបង្គន់តែពីរដងប៉ុណ្ណោះ បន្ទាប់មកដាក់សំណាកគំរូក្នុងបញ្ញើរតាមប្រៃសណីយ៍ រួចហើយលោកអ្នកបានធ្វើចប់ហើយ។”*